# មជ្ឈមណ្ឌលសិទ្ធិមនុស្សបារម្ភខ្លាចវេទិកាសាធារណៈនឹងត្រូវផ្អាក

ដោយ នុិក សារឋូរី

2010-12-21

គម្រោងវេទិកាសាធារណៈស្ដីពីសិទ្ធិមនុស្ស និងការអភិវឌ្ឍពាក់ព័ន្ធនឹងការរំលោភដីធ្លី រៀបចំដោយអង្គការសិទ្ធិមនុស្សកម្ពុជា នៅខេត្តកំពត អាចត្រូវផ្អាក ព្រោះអាជ្ញាធរមូលដ្ឋានមិនសហការផ្ដល់កន្លែងឲ្យបើកវេទិកា បន្ទាប់ពីវេទិកាសាធារណៈចំនួន២ ដែលនិយាយពីសិទ្ធិអ្នកបោះឆ្នោត និងការអភិវឌ្ឍ មិនអាចដំណើរការធ្វើវេទិកាបានកាលពីពេលថ្មីៗនេះដែរនៅខេត្តកំពត។

មន្ត្រីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក ឈឹម សារុធ បានសម្ដែងការព្រួយបារម្ភថា វេទិកាសាធារណៈដែលគម្រោងរៀបចំធ្វើនៅខេត្តកំពត នៅថ្ងៃទី២៤ ខែធ្នូ អាចត្រូវផ្អាកមិនដំណើរការដោយសារមានការសាកសួរពីអាជ្ញាធរមូលដ្ឋាន ធ្វើឲ្យមានការភ័យខ្លាចដល់អ្នកផ្ដល់កន្លែងរៀបចំវេទិកា។

លោក ឈឹម សារុធ បន្តថា ៖ *«ហើយយើងមើលស្ថានភាព ៣ថ្ងៃហ្នឹងរបស់អាជ្ញាធរនៅឃុំ ទាំងភូមិទាំងអីទាំងអស់ហ្នឹង ហាក់បីដូចជាគាត់ដើរព្យាយាមរារាំងប្រជាពលរដ្ឋមិនឲ្យចូលរួម ហើយមិនឲ្យប្រគល់ទីតាំងមកឲ្យយើងធ្វើកម្មវិធី»*។

ប្រជាជនរស់នៅភូមិត្រពាំងឈើទាល ឃុំច្រេស ស្រុកជុំគីរី ខេត្តកំពត លោក គី ហ៊ាន អាយុ ៥៣ឆ្នាំ ឲ្យដឹងនៅថ្ងៃអង្គារ ទី២១ ខែធ្នូថា គាត់សម្រេចចិត្តផ្ដល់ទីធ្លាក្នុងផ្ទះគាត់ឲ្យបើកវេទិកាសាធារណៈមួយនៅថ្ងៃ២៤ ខែធ្នូ ខាងមុខ ដើម្បីនិយាយពីការអភិវឌ្ឍតំបន់ និងបញ្ហាជម្លោះដីធ្លី ដែលរៀបចំដោយអង្គការសិទ្ធិមនុស្សកម្ពុជា។ ក្រោយពីគាត់យល់ព្រមផ្ដល់កន្លែងឲ្យបើកវេទិកាមក ៣ថ្ងៃជាប់គ្នាមានមន្ត្រីឃុំ ភូមិ និងយោធាកងពលលេខ១១២ មកសាកសួរជំទាស់នឹងការសម្រេចចិត្តរបស់គាត់នោះ។ ទោះជាយ៉ាងណា គាត់នៅតែផ្ដល់កន្លែងឲ្យបើកវេទិកានោះ ព្រោះមានលិខិតអនុញ្ញាតពីសាលាខេត្តត្រឹមត្រូវ។

លោក គី ហ៊ាន បន្ថែម ៖ *«មេឃុំក៏គេគ្រាន់ថា កុំឲ្យដាក់អីក្នុងភូមិក្នុងផ្ទះយើងអ៊ីចឹង ឲ្យដាក់ទៅកន្លែងសាធារណៈអ៊ីចឹងទៅ ហើយទាហានក៏គេថាអ៊ីចឹងដែរ។ ចំណុចគេ គេចង់ណែនាំខ្ញុំថា កាលណាដាក់នៅផ្ទះខ្ញុំក្រែងមានគេស្អប់ ទាហានអីគេស្អប់អ៊ីចឹងទៅ ព្រោះវេទិកាហ្នឹងប្រជាពលរដ្ឋគេឡើងសម្ដែងមតិប៉ះគេហើយ»*។

មន្ត្រីសមាគមការពារសិទ្ធិមនុស្សអាដហុក ខេត្តកំពត អ្នកស្រី ទ្រី ឈួន បានឲ្យដឹងថា វេទិកាសាធារណៈចំនួន២ កាលពីខែមុនត្រូវអាក់ខានបើកដូចគ្នា ដោយសារតែក្រុមអ្នកផ្ដល់ទីកន្លែងបដិសេធវិញ ក្រោយពីអាជ្ញាធរភូមិឃុំមកសាកសួរម្ចាស់សណ្ឋាគារ និងផ្ទះសំណាក់ដែលបានជួលកន្លែងឲ្យ។

ក្រុមប្រឹក្សាឃុំច្រេស ស្រុកជុំគីរី លោក ឱ សឿន អះអាងថា មិនបានទៅហាមឃាត់ម្ចាស់ផ្ទះក្នុងភូមិត្រពាំងឈើទាល មិនឲ្យបើកវេទិកាសាធារណៈនោះទេ ព្រោះសាលាឃុំបានទទួលលិខិតអនុញ្ញាតពីសាលាខេត្ត ៖ *«ធ្វើហ្នឹងមានឃើញមានច្បាប់ទម្លាប់អីរៀបចំត្រឹមត្រូវហើយ ខ្ញុំមិនមែនថា ទៅហាមឃាត់ទេ ជាសិទ្ធិរបស់ប្រជាពលរដ្ឋ សិទ្ធិរបស់ខាងមជ្ឈមណ្ឌលដែរ»*។

មេឃុំច្រេស លោក អ៊ូ សឿន មិនធ្វើអត្ថាធិប្បាយទេក្នុងការបើកវេទិកាសាធារណៈក្នុងឃុំនោះ លោកថា កំពុងនៅក្នុងប្រជុំ។

តំណាងរាស្ត្រខេត្តកំពត ខាងគណបក្សប្រជាជនកម្ពុជា លោក ឃឹម សាម៉ន មានប្រសាសន៍ថា វេទិកាសាធារណៈនៅថ្ងៃ២៤ ធ្នូ លោកនឹងមិនបានចូលរួមទេ។

សម្លេង

ខ្មែរ
អំពីវិទ្យុអាស៊ីសេរី
ព័ត៌មាន
ព័ត៌មានខ្មី
បទសម្ភាសន៍
សង្ខេបព័ត៌មានប្រចាំសប្ដាហ៍
ពហុព័ត៌មាន
វីដេអូ
វេទិកាអ្នកស្ដាប់
បទយកការណ៍
នាទីប្រចាំសប្ដាហ៍
បណ្ណសារព័ត៌មាន

POD Podcasts
RSS News Feeds

អាសយដ្ឋានអ៊ីម៉េលរបស់អ្នក
ព្រឹត្តិបត្រ

Khmer BLOG

Radio Free Asia
2025 M Street NW, Suite 300
Washington DC 20036, USA
202-530-4900
khmweb@rfa.org

ឧបករណ៍រឿង
- ស្ដាប់សំឡេង
- ថតសំឡេង
- អ៊ីម៉េល
- ចម្លងរឿងនេះទុក
- ព្រឹត្តិបត្រព័ត៌មាន
- បោះពុម្ព
- ចែករំលែករឿងនេះ

អត្ថបទដែលទាក់ទង
- ប៉ូលិសខេត្តពោធិ៍សាត់វាយដំគ្រូបង្រៀន១រូប
- ពលរដ្ឋនៅកំពង់ស្ពឺខឹងសម្បានឹងក្រុមហ៊ុនដឹកថ្ម ម៉ូហ៊ីបា
- មន្ត្រីប៉េអិមខេត្តស្ទឹងត្រែងត្រូវបានចោទថាប្រើអាវុធគំរាមអ្នកភូមិ
- CCHR ចេញសេចក្ដីថ្លែងការណ៍ចំពោះករណីសកម្មជនអាដហុក
- តុលាការសម្រេចឲ្យសកម្មជនអាដហុកចាញ់ក្ដីក្រុមហ៊ុន KDC
- របាយការណ៍ប្រចាំឆ្នាំរបស់អង្គការ Human Rights Watch
- សកម្មជនសិទ្ធិមនុស្សថាកម្ពុជាងាកឆ្ងាយពីប្រជាធិបតេយ្យ
- គ្រីស្ទហ្វ ប៉េស្ស៊ូ សង្ឃឹមថាតុលាការកាត់ក្ដីសកម្មជនសិទ្ធិមនុស្សដោយឯករាជ្យ
- ជុំវិញការបិទគេហទំព័រ KI-Media និង blogspot.com
- ឆ្នាំ២០១០ចំនួនអ្នកទោសស្លាប់ក្នុងពន្ធនាគារកើនឡើង

រឿងដែលគេអានច្រើនបំផុត
- ខ្មែរ-ថៃប្រឈមមុខដាក់គ្នាសាជា
- សម រង្ស៊ី មានគម្រោងប្ដឹង ហ៊ុន សែន
- ថៃប៉ុនប៉ងដាក់ទង់ជាតិរបស់ខ្លួ
- ខ្មែរបញ្ជូនកងទ័ព និងសព្វាវុធទៅ
- សមិទ្ធផល២៦ឆ្នាំក្រោមការដឹកនា

លោកបន្តថា ៖ *«វេទិកាបែបនេះចំណេញបានភាគីជំទាស់ដែរ ប្រមាថតែគណបក្សកាន់អំណាចហ្នឹង មានបានចំណេញអី»*។

តំណាងរាស្ត្រគណបក្ស សម រង្ស៊ី លោកស្រី មូរ សុខហួរ មានប្រសាសន៍ថា អ្នកតំណាងរាស្ត្រគ្រប់គណបក្សនយោបាយក្រោយជាប់ឆ្នោតនៅតំបន់របស់ខ្លួនត្រូវតែទទួលយក និងស្ដាប់ទុក្ខកង្វល់ពីរាស្ត្រតាមរយៈការសម្ដែងមតិក្នុងវេទិកាសាធារណៈនោះ។

មន្ត្រីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក ឈឹម សារុធ ឲ្យដឹងថា កាលពីខែមុន វេទិកាសាធារណៈស្ដីពីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិអ្នកបោះឆ្នោតត្រូវបានម្ចាស់សណ្ឋាគារ និងផ្ទះសំណាក់ ៣ កន្លែងសុំសងប្រាក់កក់មកវិញ មិនហ៊ានជួលទីតាំងឲ្យធ្វើវេទិកាទេ។ អង្គការនេះបានសម្រេចបញ្ឈប់វេទិកាវិញ ព្រោះតក់ក្រហល់គ្មានកន្លែងសម្រាប់បើកវេទិកា។

លោក ឈឹម សារុធ បន្តថា វេទិកានេះបានធ្វើចំនួន ២៥ខេត្តក្រុង បានចំនួនជាង ១០ប្រធានបទមកហើយ។ ក្នុងនោះមានវគ្គសិក្ខាសាលាជាង ២០កម្មវិធី ដែលផ្ដោតលើសិទ្ធិអ្នកបោះឆ្នោត ច្បាប់អនុវត្តក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍជាដើម។ ប៉ុន្តែបញ្ហាកើតមាននៅខេត្តកំពត គឺថ្នាក់ខេត្តសហការល្អ តែថ្នាក់ភូមិឃុំច្រើនតែបង្កការលំបាក៕

*Copyright © 1998-2011 Radio Free Asia. All rights reserved.*

**បោះពុម្ព** **អ៊ីម៉េល**

## រឿងដែលគេអ៊ីម៉េលច្រើនបំផុត

- សម រង្ស៊ី មានគម្រោងប្ដឹង ហ៊ុន សែន
- រយៈពេល២៦ឆ្នាំនៃការកាន់អំណាច
- សមិទ្ធផល២៦ឆ្នាំក្រោមការដឹកនាំ
- IRI៖ ៧៦% នៃពលរដ្ឋខ្មែរយល់ថារដ្ឋ
- ខ្មែរបញ្ជូនកងទ័ព និងសព្វាវុធទៅ

**មតិ**

Click here to add your own comment

មើលមតិទាំងអស់.

បញ្ចូលមតិរបស់អ្នកដោយបំពេញទម្រង់ខាងក្រោមជាអក្សរសុទ្ធ។
មតិនឹងត្រូវសម្រេចដោយអ្នកសម្របសម្រួលនិងអាចចុះផ្សាយបានយោងតាមលក្ខខណ្ឌនៃការប្រើប្រា
មតិនឹងមិនអាចមើលឃើញភ្លាមៗទេ។
វិទ្យុអាស៊ីសេរីមិនទទួលខុសត្រូវចំពោះខ្លឹមសារនៃមតិដែលបានចុះផ្សាយឡើយ។

ឈ្មោះ (ដាក់ឬមិនដាក់ក៏បាន)

ក្រុង (ដាក់ឬមិនដាក់ក៏បាន)

Captcha (ត្រូវតែបំពេញ)

UZU40V6

*សូមវាយបញ្ចូលតួអក្សរដែលអ្នកឃើញនៅក្នុងរូបភាព*

មតិ (ត្រូវតែបំពេញ)

Submit